# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង សំរាប់ដោះស្រាយបាតុភាពអសកម្ម មួយចំនួន នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងលទ្ធផលនៃកិច្ចប្រជុំអន្តរក្រសួង នាថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៣នៅទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ១ :** បង្កើតក្រុមការងារអន្តរក្រសួងមួយ សំរាប់ដោះស្រាយបាតុភាពអសកម្មមួយចំនួន នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ ប្រធាន

២-ឯកឧត្តម **នីយ ផឿន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល អនុប្រធាន

៣-ឯកឧត្តម **ស៊ឹម ស្វួន** តំណាងអាជ្ញាធរជាតិទេសចរណ៍ អនុប្រធាន

៤- ឯកឧត្តម **អ៊ឹក ចាន់** អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៥- ឯកឧត្តម **សូ ម៉ារ៉ា** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ សមាជិក

៦- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃៀំ សុជាតិ** តំណាងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

៧- ឯកឧត្តម **អន ស៊ុំ** អភិបាលរងទី១ ខេត្តបន្ទាយមានជ័យ សមាជិក

៨- ឯកឧត្តម **ឌុច ចនធីតូ** អគ្គនាយករៀបចំដែនដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៩-លោកឧត្តមសេនីយ៍ត្រី **មៀច សុផាន់ណា** ប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ សមាជិក

១០-លោក **ហួយ គីឡូនុះ** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ សមាជិក

១១-លោក **ស៊ុត តារា** ប្រធាននាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម សមាជិក

១២-លោក **ឡាយ ប្ញទ្ធី** នាយករងទីចាត់ការគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៣-លោក **ស ម៉ឺន** អភិបាលស្រុកអូរជ្រៅ សមាជិក

**ប្រការ២** : ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ច :

-សិក្សា និងវាយតំលៃអំពីផលប៉ះពាល់ដល់ភ្ញៀវទេសចរអន្តរជាតិ និងគោលនយោបាយទេសចរណ៍ជាតិ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្ត បន្ទាយមានជ័យ

-ស្រាវជ្រាវ និងពិនិត្យរកដំណោះស្រាយ លើបញ្ហាវិធីសំរាប់រៀបចំចំណតរថយន្តទេសចរណ៍ និងកន្លែងរង់ចាំរបស់ភ្ញៀវទេសចរ

-ស្រាវជ្រាវ និងសិក្សាបន្ថែមទៅលើច្រកទ្វារ និងកសាងផ្លូវពង្វាងមួយ ដែលមិនមែនជាច្រកថ្មី សំរាប់ប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ចេញ-ចូលដោយគ្មានទិដ្ឋាការ និងការដឹកជញ្ជូនទំនិញឆ្លងកាត់របស់ពុះជន ដោយរក្សាទុកច្រកទ្វារបច្ចុប្បន្ននេះ សំរាប់ភ្ញៀវទេសចរធ្វើដំណើរឆ្លងកាត់

-បូកសរុបលទ្ធផល និងធ្វើរបាយការណ៍ ដោយលើកយោបល់ជាវិធានការដោះស្រាយ ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

**ប្រការ៣ :** ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិកាក្នុងការងាររបស់ក្រសួងទេសចរណ៍ និងមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ជាជំនួយការ ។

- លេខាធិការដ្ឋាននេះ មានទីតាំងនៅទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**ប្រការ៤ :** សមាជិកក្រុមការងារអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១៨ ខែ កុម្ភៈ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :***

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ៥*

*-កាលប្បវត្តិ-ឯកសារ*

/ll.